សលាកប័ត្រព័ត៌មាន NEWSLETTER
លេខៈ ៥១ ខែមិថុនា ឆ្នាំ២០១០
Issue: 51 June 2010

ឃ្លាំមើល សាលាក្តីខ្មែរក្រហម
KHMER ROUGE TRIBUNAL (KRT) WATCH

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ_សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - BCV - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CJR - CSD - CWCC - GENEROUS - HROTP - IDA - KKKHRO - KKKHRDA - KID - KIND - KSA - KYA - LAC - PDP -PJJ - VIGILANCE

# ពេលវេលាប្រកាសសាលក្រម ឌុច នឹងមកដល់

## *Duch's Verdict Pronouncement Up Comming*

ប្រធានមន្ទីរស-២១ ឈ្មោះ **កាំង ហ្កេកអ៊ាវ** ដែលមាន ឈ្មោះបដិវត្តន៍របស់គាត់ថាជា "**ឌុច**" ត្រូវបាន សាលាដំបូង នៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បើកសវនាការជំនុំជម្រះ ចាប់តាំងពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ កន្លងទៅ។ បើយោងទៅតាមសេចក្តីប្រកាសជាផ្លូវការ របស់ផ្នែកកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញ បាន គូសបញ្ជាក់ថា ចៅក្រម នៃ សាលាដំបូង នឹងបើកសវនាការប្រកាសសាលក្រមទៅលើជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០** នៅវេលាម៉ោង **១០:០០ ព្រឹក** ខាងមុខនេះ។



*ជនជាប់ចោទ **ឌុច** នៅក្នុងសាលសវនាការសាលាដំបូង*

ពេលវេលាប្រកាសសាលក្រម គឺជាពេលវេលាដ៏សំខាន់សម្រាប់ជនរងគ្រោះទាំងឡាយ នៃ របបខ្មែរក្រហម ដែលបានទន្ទឹងរង់ចាំអស់រយៈពេលដ៏យូរ ក្រោយពេលដែលរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ កាលពីជាង ៣១ឆ្នាំ មុន។ សាលក្រមនេះ នឹងកំណត់ជាផ្លូវការថាតើ ជនជាប់ចោទអ្នកទទួលខុសត្រូវខ្មែរក្រហមដំបូងគេ **ឌុច** មានពិរុទ្ធភាព (មានទោស) ឬមិនមានពិរុទ្ធភាព (គ្មានទោស)។ ប្រសិនបើរកឃើញ ថាមានទោស នោះ តុលាការនឹងកំណត់អំពីប្រភេទបទចោទប្រកាន់ និងបទឧក្រិដ្ឋដែលជនជាប់ចោទរូបនេះទទួលខុសត្រូវនៅក្នុងរយៈកាល ដែលគាត់កាន់កាប់អំណាចជាប្រធានមន្ទីរសន្តិបាល (មន្ទីរ-២១) ព្រមទាំងទំហំទោស ដែលត្រូវបានផ្តន្ទាទោសដោយតុលាការផងដែរ។

នៅក្នុងចំណោមមេដឹកនាំខ្មែរក្រហមចំនួន ៥ រូប ដែលត្រូវ បានដាក់នៅក្នុងមន្ទីរឃុំខ្លួនបណ្តោះអាសន្ន របស់អង្គជំនុំជម្រះវិសាមញ្ញ មានតែជនជាប់ចោទ **ឌុច** ទេ ដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការជំនុំជម្រះ។ ជនជាប់ចោទ **ឌុច** ដែលមានអាយុ ៦៨ ឆ្នាំ ត្រូវបានតុលាការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម, អំពើមនុស្សឃាត, អំពើទារុណកម្ម និងអំពើធ្វើទុក្ខបុកម្នេញដទៃទៀត នៅក្នុងរយៈកាលដែលគាត់កាន់កាប់អំណាចនៅមន្ទីរស-២១ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អំពើឧក្រិដ្ឋកម្មទាំងនេះ សុទ្ធតែមានលក្ខណៈធ្ងន់ធ្ងរ និងប្រឆាំងមនុស្សជាតិ ដែលត្រូវបានប្រព្រឹត្តខុសទៅនឹងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលត្រូវបានយកមក អនុវត្តន៍ដោយអង្គជំនុំជម្រះវិសាមញ្ញ តាមរយៈច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ។

ដើម្បីឱ្យសាធារណជនជាតិ និងអន្តរជាតិ ជាពិសេសជនរងគ្រោះ នៃរបបខ្មែរក្រហមទាំងអស់ គឺទាំងអ្នកដែលបានចូលរួមដាក់ពាក្យបណ្តឹងជា ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩៣ រូប និង ជនរងគ្រោះផ្សេងទៀត ដែលមិនបានដាក់ពាក្យបណ្តឹងតាមដាននូវ ព្រឹត្តិការណ៍សវនាការ នៃការប្រកាសសាលក្រមប្រឆាំងនឹងជនជាប់ ចោទ ឌុច នៅ ថ្ងៃទី២៦ ខែកក្កដា ខាងមុខនេះ ទាំងខាងផ្នែកកិច្ចការសាធារណៈ នៃអង្គជំនុំជម្រះវិសាមញ្ញ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលធ្វើការលើវិស័យនេះបានខិតខំត្រៀមបំរុង និង រៀបចំនូវសកម្មភាពសំខាន់ៗជាច្រើនចាប់តាំងពីមុនពេល កំឡុងពេល និងក្រោយពេលប្រកាសសាលក្រម។

បើតាមមន្ត្រីអ្នកនាំពាក្យរបស់អង្គជំនុំជម្រះវិសាមញ្ញ លោក **ឌីម សុវណ្ណារុំ** បានគូសបញ្ជាក់ថា ការិយាល័យរបស់លោកបានត្រៀមបំរុងនូវសកម្មភាពផ្សព្វផ្សាយជាច្រើន ដោយមានកិច្ចសហការ និងសម្របសម្រួលជាមួយនឹងអង្គការសង្គមស៊ីវិល ផងដែរ។ លោកបានគូសបញ្ជាក់ថា សកម្មភាពទាំងនោះរួមមានៈ ការផលិតជាខ្សែវីដេអូ រយៈពេល១០នាទី

ដែលឆ្លុះបញ្ចាំងនូវទិដ្ឋភាពសំខាន់ៗ នៃសវនាការ សំណុំរឿង០០១ ដែលនឹងត្រូវចែកជូនទៅកាន់បណ្ដាស្ថានីយ៍ទូរទស្សន៍ សម្រាប់ការចាក់ផ្សាយនៅមុនពេលប្រកាសសាលក្រម។ ក្រៅពីនេះ ក៏មានការផលិតជាកម្មវិធីឃ្លីបខ្លីរយៈពេល១នាទី ផ្សព្វផ្សាយអំពីការប្រកាសសាលក្រមដែលនឹងមកដល់ពេលខាងមុខ សម្រាប់ផ្សាយតាមរយៈកម្មវិធីវិទ្យុ, និងចុះផ្សាយនៅតាមទំព័រកាសែតជាដើម។ លោកបានគូសបញ្ជាក់ថា នៅថ្ងៃប្រកាសសាលក្រមផ្ទាល់ ការិយាល័យរបស់លោក ក៏បានរៀបចំផ្សាយបន្តផ្ទាល់ទៅកាន់ស្ថានីយ៍ទូរទស្សន៍ និងវិទ្យុ ជាតិ ផងដែរ សម្រាប់បងប្អូនប្រជាពលរដ្ឋយើង ដែលមិនអាចអញ្ជើញ មកចូលរួមស្ដាប់សវនាការដោយផ្ទាល់នៅឯអង្គជំនុំជម្រះវិសាមញ្ញ ដោយសារតែសាលសវនាការស្ថិតនៅឆ្ងាយពីលំនៅដ្ឋានរបស់គាត់ និង គួបផ្សំកន្លែងអង្គុយមានកំរិត (ជាង ៥០០កន្លែង) ផងនោះ។

លោក **សុក សំអឿន** នាយកប្រតិបត្តិ នៃ អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) ដែលអង្គការរបស់លោកក៏បានចូលរួមចំណែក នៅក្នុងដំណើរការកាត់សេចក្ដីប្រឆាំងនឹងជនជាប់ចោទ តាមរយៈការផ្ដល់មេធាវីជាតិចំនួនពីររូបតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ផងនោះ បានសំដែងនូវការអបអរសាទរចំពោះដំណឹងនេះ បើទោះបីជា ត្រូវបានចំណាយពេលវេលាយូរបន្តិច ចាប់ពីពេលបញ្ចប់សវនាការកាលពីអំឡុងឆ្នាំមុនក៏ដោយ។ លោកបានសំដែងទស្សនៈថា សាលក្រមដែលនឹងត្រូវប្រកាសឡើងដោយចៅក្រម នៃអង្គជំនុំជម្រះសាលាដំបូង នៅ ថ្ងៃទី២៦ ខែកក្កដា នេះ វាមានសារៈសំខាន់ខ្លាំងណាស់ ជាពិសេស សម្រាប់ជនរងគ្រោះទាំងឡាយនៃរបបខ្មែរក្រហម ដែលបានទន្ទឹងរង់ចាំអស់រយៈពេលជាង៣០ឆ្នាំ។ សារៈសំខាន់របស់សាលក្រមនេះ គឺថា វាជាឯកសារផ្លូវច្បាប់តែមួយគត់ ដែលចេញដោយអង្គជំនុំជម្រះវិសាមញ្ញ ដែលជាតុលាការមានសមត្ថកិច្ចជំនុំជម្រះទៅលើឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម ដែលបានប្រព្រឹត្តដោយមេដឹកនាំជាន់ខ្ពស់ និង អ្នកទទួលខុសត្រូវខ្ពស់បំផុត ដើម្បីសម្រេចថាតើ អតីតប្រធានមន្ទីរស-២១ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ពិតជាមានទោស ឬគ្មានទោស។ ប្រសិនបើត្រូវរកឃើញថា មានទោស គឺថា តាមរយៈសាលក្រមនេះ ចៅក្រមនឹងសម្រេចអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ និងទំហំទោស ដែលជនជាប់ចោទត្រូវទទួលផងដែរ។ លើសនេះ ចៅក្រមក៏នឹងសម្រេចអំពីប្រភេទនៃសំណងរដ្ឋប្បវេណីសម្រាប់ជនរងគ្រោះដែលបានដាក់ពាក្យប្ដឹងជាដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ លោកក៏បានសំដែងមតិថា ចំពោះការសម្រេចបែបណាលើករណីនេះ យើងត្រូវរង់ចាំមើលទាំងអស់គ្នា ថាតើ មានយុត្តិធម៌កំរិតណា ឬថាតើ យុត្តិធម៌នោះត្រឹម ត្រូវឬទេ ? ពីព្រោះថា សម្រាប់ជនរងគ្រោះ វាជាការសំខាន់ក្នុងការយល់ដឹងពីអំពីអត្ថន័យនៃការកាត់សេចក្ដី និងការសម្រេចរបស់ចៅក្រម ដើម្បីអាចឱ្យខ្លួនធ្វើការវាយតំលៃដោយផ្ទាល់ ប្រៀបធៀបនឹងអង្គហេតុ និងភស្តុតាង សាក្សី ដែលមាន។

លោក **សុក សំអឿន** ក៏បានពន្យល់ បន្ថែមទៀតថា ដូចនេះ វាមានសារៈសំខាន់ណាស់ចំពោះជនរងគ្រោះ ជាពិសេសដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ ត្រៀមលក្ខណៈទុកជាមុន អំពីលទ្ធផលនៃសាលក្រមនេះ ពីព្រោះថា ការសម្រេចរបស់ចៅក្រម អាចនឹងមិនត្រូវចិត្តចំពោះការចង់បានទាំងស្រុង ឬខុសពីការរំពឹងទុករបស់ខ្លួន ។ ម្យ៉ាងទៀត តាមទស្សនៈផ្លូវច្បាប់ ប្រសិនបើជនជាប់ចោទ **ឌុច** ត្រូវបានតុលាការផ្ដន្ទាទោសមែននោះ ហើយប្រសិនបើមិនសុខចិត្តនឹងសាលក្រមនេះ ជនជាប់ចោទរូបនេះនៅមានសិទ្ធិមួយ ទៀត គឺសិទ្ធិប្ដឹងសាទុក្ខ (ប្ដឹងឧទ្ធរណ៍) ទៅអង្គជំនុំជម្រះតុលាការកំពូលទៀត។ ដូចគ្នាដែរ ប្រសិនបើភាគីសហព្រះរាជអាជ្ញា នៃរឿងក្ដី ០០១នេះ មិនពេញចិត្តចំពោះសាលក្រមនេះ លោកក៏អាចប្ដឹងសាទុក្ខទៅតុលាការកំពូលផងដែរ ដោយបញ្ជាក់នូវហេតុផលច្បាប់ត្រឹមត្រូវ។

គួរបញ្ជាក់ថា នៅក្នុងពេលជំនុំជម្រះនៅក្នុងសវនាការដែលបានប្រព្រឹត្តធ្វើឡើងអស់រយៈពេល ៧៧ ថ្ងៃ ដោយអង្គជំនុំជម្រះសាលាដំបូង កាលពី ឆ្នាំ២០០៩ កន្លងទៅ មានជនរងគ្រោះចំនួន ៩៣ រូប ត្រូវបានតុលាការទទួលស្គាល់ជា ភាគីដើមបណ្ដឹងរដ្ឋប្បវេណី ( បានដាក់ពាក្យបណ្ដឹងប្រឆាំងនឹងជនជាប់ចោទ ដែលជាអ្នកទទួលខុសត្រូវចំពោះការបាត់បង់ក្រុមគ្រួសារ សាច់ញាតិ និងបានរងគ្រោះដោយផ្ទាល់ នៅឯមន្ទីរស-២១ ឬមន្ទីរឃុំឃាំង នេះ)។ ក្រៅពីភស្តុតាង ជាវត្ថុតាង និងឯកសារ ជាច្រើន នៅមានសាក្សីរស់ជាច្រើនរូបទៀត ដែលធ្លាប់ជាអតីតកម្មាភិបាលខ្មែរក្រហមនៅមន្ទីរស-២១ និងសាក្សីជាអ្នកជំនាញ ជាតិ និងអន្តរជាតិ ក៏ត្រូវបានកោះអញ្ជើញមកបំភ្លឺចំពោះឧក្រិដ្ឋកម្មនានា ដែលបានកើតឡើងនៅក្នុងមន្ទីរស-២១ និងអាកប្បកិរិយារបស់ជនជាប់ចោទ នៅក្នុងសវនាការជាសាធារណៈមួយ ផងដែរ។

យោងទៅតាមឯកសារជាផ្លូវការរបស់តុលាការ បានគូសបញ្ជាក់ថា ជនជាប់ចោទ **ឌុច** ត្រូវបានចោទប្រកាន់ និងត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានាដែលបានកើតឡើងនៅមន្ទីរស-២១ ដែលក្នុងនោះ មានជនរងគ្រោះប្រមាណជាង ១២,៣៨០ នាក់ ត្រូវបានធ្វើទារុណកម្ម, រងនូវការធ្វើទុក្ខបុកម្នេញយ៉ាងអមនុស្សធម៌ និង បន្ទាប់មក ត្រូវបានគេបញ្ជូនទៅសំលាប់រង្គាលយ៉ាងសាហាវឃោរឃៅ នៅឯមន្ទីរនេះ និងវាលពិឃាតជើងឯក។ យោងទៅតាមចំលើយរបស់ជនជាប់ចោទបំភ្លឺនៅចំពោះមុខអង្គចៅក្រម នៃ អង្គជំនុំជម្រះសាលាដំបូង អក្សរ “**ស**” មានន័យថាជា “**សន្តិបាល**” ដែលជា

ទំរង់ ថ្មីមួយ នៃកំលាំងសន្តិសុខ បង្កើតឡើងដោយខ្មែរក្រហម ដើម្បីការពារសន្តិភាព និងសន្តិសុខជាតិ។ ដូចនេះ មន្ទីរស-២១ គឺជាគុក សន្តិសុខ ដ៏សំខាន់មួយរបស់ខ្មែរក្រហម ដែលមានទំរង់ដូចមន្ទីរ ម-១៣ ដែរ ប៉ុន្តែមន្ទីរនេះ ត្រូវបានប្រើប្រាស់ដោយខ្មែរក្រហមថ្នាក់លើ ដើម្បីកំទេច ឬសម្លាប់សត្រូវដែលចាប់បាននៅក្នុងរបបនោះ។ នៅក្នុងសវនាការ នាពេលនោះ ជនជាប់ចោទ **ឌុច** បានថ្លែង ទទួលស្គាល់ថា ខ្លួនជាប្រធាន មន្ទីរស-២១ ចាប់តាំងពីខែមីនា ឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៩ ហើយបន្ថែមពីនេះ គាត់ក៏បាន បញ្ជាក់ថា នៅចន្លោះឆ្នាំ ១៩៧៦ ដល់ ឆ្នាំ១៩៧៧ ខ្លួនបានសម្រេច ផ្លាស់ប្តូរទីតាំងសំលាប់មនុស្សពីមន្ទីរស-២១ ទៅកាន់មន្ទីរជើងឯក វិញ ដែលមានចំងាយប្រមាណ ១៥ គីឡូម៉ែត្រ ខាងត្បូងទីក្រុង ភ្នំពេញ។ ចំណែកឯទីតាំងមួយទៀត ត្រូវបានគេស្គាល់ ថាជា មន្ទីរ ស-២៤ ឬគុកព្រៃស ដែលក៏ជាផ្នែកមួយ នៃមន្ទីស-២១ ផងដែរ ដែលត្រូវបានប្រើប្រាស់ជាជំរុំអប់រំកែប្រែជាថ្មី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

អ្វីដែលជាកត់សំគាល់មួយទៀតគឺថា នៅក្នុងសវនាការ ប៉ុន្មាន ថ្ងៃដំបូង ជនជាប់ចោទ **ឌុច** បានឆ្លើយសារភាព និងបាន សំដែងនូវ វិប្បដិសារីចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងទៅលើ ជនរងគ្រោះ និង បានសំដែងនូវការសុំអភ័យទោសពីជនរងគ្រោះ និងសាច់ញាតិរបស់ ជនរងគ្រោះ ផងដែរ។ ប៉ុន្តែ ទោះបីជាយ៉ាងនេះ ក៏នៅពេលនោះ មានជនរងគ្រោះជាច្រើន ដែលចូលរួមផ្ទាល់ជាដើម បណ្តឹងរដ្ឋប្បវេណី បានសំដែងនូវការមិនសប្បាយចិត្ត ចំពោះទង្វើ របស់ជនជាប់ចោទទេ ពីព្រោះ គេចាត់ទុកថា ការឆ្លើយរបស់ **ឌុច** នៅចំពោះមុខអង្គចៅក្រម មិនបានបង្ហាញនូវការពិតអំពីទំហំឧក្រិដ្ឋកម្ម និងភាពរងទុក្ខ ដែលគេ បានទទួល នាពេលនោះឡើយ។ គេនៅតែ សំណូមពរដល់អង្គជំនុំជម្រះ សាលាដំបូងស្វែងរកយុត្តិធម៌ជូនគេ ព្រមទាំង ជនរងគ្រោះទាំងឡាយ ដែលបានរងគ្រោះនៅក្រោម ការគ្រប់គ្រង និងការទទួលខុសត្រូវផ្ទាល់របស់ជនជាប់ចោទរូបនេះ។

## បញ្ហាប្រឈមបច្ចុប្បន្នទាក់ទិននឹងការចូលរួម របស់ជនរងគ្រោះនៅក្នុង សាលាក្ដីខ្មែរក្រហម

### Current Challenges in Victims Participation at the ECCC

នៅខណៈពេលដែល អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម កំពុងតែបន្តដំណើរទៅមុខ បំពេញនូវបេសកកម្ម ស្វែងរកយុត្តិធម៌ជូនរងគ្រោះដោយសាររបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម ជាពិសេស ព្រឹត្តិការណ៍សំខាន់ៗពីរ គឺ ពេលវេលា នៃ ប្រកាសសាលក្រម ប្រឆាំងនឹងជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** នៅក្នុងសំណុំរឿង ០០១ នៅថ្ងៃទី២៦ ខែកក្កដា និង ការគ្រោងចេញដីកាបញ្ជូនរឿងឱ្យជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតសម្រាប់សំណុំរឿង ០០២ នៅអំឡុងខែកញ្ញា ឆ្នាំ២០១០ យើងសង្កេតឃើញថា នៅមានបញ្ហាប្រឈមមួយចំនួននៅឡើយ ពាក់ព័ន្ធនឹងការចូលរួមរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី សំណុំ រឿង០០២ នេះ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ និងដោះស្រាយឱ្យទាន់ពេលវេលាផងដែរ។

ក្នុងរយៈពេលកន្លងមកនេះ មានកិច្ចខិតខំប្រឹងប្រែជាច្រើន ដែលធ្វើឡើងដោយអង្គជំនុំជម្រះវិសាមញ្ញ ជាពិសេស អង្គភាពគាំពារជនរងគ្រោះ ដោយធ្វើការសហការយ៉ាងសកម្មជាមួយនឹងក្រុមអង្គការ មិនមែនរដ្ឋាភិបាល (អង្គការអន្តរការី) និងសហមេធាវីជាតិ និងអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការចុះប្រមូលយកព័ត៌មានបន្ថែមសម្រាប់ទំរង់ពាក្យបណ្តឹងរបស់ជនរងគ្រោះដែលសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ ព្រមទាំងរៀបចំធ្វើលិខិតពឹងពាក់សហមេធាវីតំណាងអ្នកដាក់ពាក្យសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ដែលទើបតែបញ្ចប់ទៅថ្មីៗនេះ។

ទន្ទឹមនឹងជំហានវិជ្ជមាននេះ សង្គមស៊ីវិលកត់សំគាល់ឃើញថា នៅមានបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលត្រូវយកចិត្តទុកដាក់ដោះ ស្រាយបានឆាប់រហ័សដែរ។ បញ្ហាទីមួយ គឺទាក់ទិន អ្នកដាក់ពាក្យសុំខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណិ ដែលមិនទាន់មាន មេធាវីតំណាងមានចំនួនប្រហែល ២០%ទៀត នៅក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សំណុំរឿងទាំងអស់មានជាង ៤០០។ លទ្ធផលដូចនេះ ក៏អាចបណ្តាលមកពីសមត្ថភាព និងលទ្ធភាពទទួលការពារក្តីរបស់សហមេធាវីជាតិ និង អន្តរជាតិបច្ចុប្បន្នមានកំរិត ស្របទៅតាមធនធានថវិកា និងពេលវេលារបស់គេ និងបញ្ហាកង្វះមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បន្ថែមទៀត ដែលកំពុងតែធ្វើការជ្រើសរើសនៅឡើយ។ ដូចនេះ ដើម្បីដោះស្រាយបញ្ហានេះឱ្យបានត្រឹមត្រូវ និង មានយុត្តិធម៌សម្រាប់ជនរងគ្រោះទាំងនោះ សង្គមស៊ីវិលយល់ថា អង្គជំនុំជម្រះវិសាមញ្ញ គួរពន្លឿនល្បឿននៃការជ្រើសរើសមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមឱ្យកាន់តែឆាប់រហ័សជាងនេះ។ ម្យ៉ាងទៀត អង្គជំនុំជម្រះវិសាមញ្ញ ក៏ត្រូវយកចិត្តទុកដាក់ទៅលើការជ្រើសរើសឱ្យបានឆាប់

រហ័សផងដែរនូវ សហមេធាវីនាំមុខតំណាងដើម បណ្តឹងរដ្ឋប្បវេណី (មេធាវីជាតិម្នាក់និង មេធាវីអន្តរជាតិម្នាក់) ដែលនឹងត្រូវដើរតួសំខាន់នៅក្នុងសវនាការកាត់សេចក្តីសំណុំរឿង០០២ ដើម្បីឱ្យគេចូលបំពេញតួនាទីដ៏សំខាន់ និងមានពេលវេលាគ្រប់គ្រាន់ ក្នុងការរៀបចំយុទ្ធសាស្ត្រនានា សម្រាប់ការពារផលប្រយោជន៍ដល់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីដោយធ្វើការសហការយ៉ាងជិតស្និតជាមួយសហមេធាវីតំណាងក្រុមដើមបណ្តឹងរដ្ឋប្បវេណីបច្ចុប្បន្ន។

បញ្ហាប្រឈមទីពីរ ដែលអង្គជំនុំជម្រះវិសាមញ្ញត្រូវយកចិត្តទុកផងដែរនោះ គឺការជ្រើសរើសដោយតម្លាភាព ដោយត្រឹមត្រូវ និងឱ្យបានឆាប់រហ័សនូវតួនាទីប្រធានថ្មីនៃអង្គភាពគាំពារជនរងគ្រោះ ពីព្រោះថា បច្ចុប្បន្ននេះ អង្គភាពនេះ ត្រូវដឹកនាំដោយប្រធានស្តីទីបណ្តោះអាសន្ន បន្ទាប់ពីប្រធានចាស់ លោកស្រី **ហេឡែន ចារីស** បានសុំចូលនិវត្តន៍ និងបានឈប់ពីការងារពីចុងខែមិថុនា កន្លងទៅនេះ។ អង្គការសង្គមស៊ីវិលយល់ថា ការដែលទុកពេលយូរពេកក្នុងការជ្រើសតាំងប្រធានថ្មីសម្រាប់អង្គភាពនេះ ក៏អាចជាកង្វល់មួយដែលវាអាចធ្វើឱ្យប៉ះពាល់ដល់និរន្តភាពការងារ និងអាណត្តិការងាររបស់អង្គភាពក្នុងបំពេញតួនាទីជួយគាំទ្រ និងការពារផលប្រយោជន៍របស់ជនរងគ្រោះ ដែលបានចូលរួមនៅក្នុងដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញបច្ចុប្បន្នឱ្យបានពេញលេញ។

បញ្ហាទីបី គឺបញ្ហាថវិការបស់អង្គជំនុំជម្រះវិសាមញ្ញទាំងមូលដែលនៅតែខ្វះខាត នៅខណៈពេលដែលពេលវេលាសំខាន់សម្រាប់បញ្ចប់សំណុំរឿង០០១ និងឈានទៅចាប់ផ្តើមសំណុំរឿង០០២នេះ។ ទោះបីជានៅពេលថ្មីៗនេះ ប្រទេសមួយចំនួន ដែលជាសមាជិករបស់អង្គការសហប្រជាជាតិ ដូចជា ប្រទេសជប៉ុន ទើបតែផ្តល់ថវិកាជូនភាគីកម្ពុជា នៃសាលាក្តី ជាង ២ លាន ដុល្លារសហរដ្ឋអាមេរិក និងមានកិច្ចព្រមព្រៀងធ្វើឡើងរវាងអង្គភាពគាំពារជនរងគ្រោះ និងម្ចាស់ជំនួយរដ្ឋាភិបាលអាឡឺម៉ង់ជាង ៤០ ម៉ឺនដុល្លារសហរដ្ឋអាមេរិកក្នុងការបន្តជួយអង្គភាពគាំពារជនរងគ្រោះក៏ដោយ ក៏ថវិកាទាំងនេះនៅមិនទាន់គ្រប់គ្រាន់សម្រាប់បំពេញតំរូវការនៅឡើយ។ ដូចនេះ ជាមួយនឹងបញ្ហានេះ សង្គមស៊ីវិល នៅតែមានសង្ឃឹមថា ប្រទេសម្ចាស់ជំនួយនានា នឹងបន្តគាំទ្រផ្តល់ថវិកាជាបន្តបន្ទាប់ដល់សាលាក្តីនេះ ដើម្បីឱ្យវាអាចបំពេញតួនាទីដ៏មានសារៈសំខាន់សម្រាប់ស្វែងរកយុត្តិធម៌ចំពោះជនរងគ្រោះ ដែលបាននឹងកំពុងតែទន្ទឹងរង់ចាំអស់រយៈពេលដ៏យូរ។ លើសពីនេះទៀត ការបន្តឱ្យមាននិរន្តភាព និងដំណើរទៅមុខរបស់អង្គភាពនេះ ក៏ដើម្បីឱ្យវាបំពេញអាណត្តិក្នុងការអនុវត្តន៍គំរោងផ្សេងៗ ដែលនឹងត្រូវ ចេញដោយអង្គជំនុំជម្រះវិសាមញ្ញនាពេលខាងមុខនេះផងដែរ។

បញ្ហាចុងក្រោយ គឺបញ្ហាសំណង (សំណងរដ្ឋប្បវេណី) ដែល នឹងកើតចេញពីការសម្រេចរបស់អង្គជំនុំជម្រះវិសាមញ្ញ ពីព្រោះថា នៅខណៈនេះ វានៅតែជាបញ្ហាស្រពិចស្រពិលនៅឡើយ ដោយសារតែវិធានផ្ទៃក្នុង ដែលជាច្បាប់របស់តុលាការ នៅមិនទាន់ចែងលំអិតឱ្យបានច្បាស់លាស់អំពីទំរង់នៃសំណង និងមធ្យោបាយក្នុងការអនុវត្តន៍ជាក់ស្តែង។ កន្លងមកមានការជជែកពិភាក្សាគ្នា ជាច្រើនលើកច្រើនសារនៅក្នុងចំណោមអង្គការសង្គមស៊ីវិល និងអ្នកជំនាញជាតិ និងអន្តរជាតិ ព្រមទាំងមន្ត្រីចៅក្រម នៃ អង្គជំនុំជម្រះវិសាមញ្ញ ដើម្បីបង្កើតឱ្យបាននូវបទប្បញ្ញត្តិ និងយន្តការនានាជុំវិញបញ្ហាសំណងសម្រាប់ ជនរងគ្រោះ នៃរបបខ្មែរក្រហម ជាពិសេសអ្នកដាក់ពាក្យបណ្តឹង។

ដូចនេះ ដើម្បីឱ្យបញ្ហាសំណងអាចចេញជារូបរាងពិតប្រាកដសម្រាប់ជាផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ នៃរបបខ្មែរក្រហម សង្គមស៊ីវិលសង្ឃឹមថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានអាណត្តិពិសេសក្នុងការផ្តន្ទាទោសជនជាប់ ចោទ និងចេញសេចក្តីសម្រេចពីបញ្ហាសំណងជូនដល់ជនរងគ្រោះ ដែលបានដាក់ពាក្យប្តឹង នឹងបន្តស្វែងរកមធ្យោបាយសំខាន់ៗផ្សេងទៀត ដើម្បីអាចឱ្យគេអនុវត្តន៍បានលើសពីអ្វីដែលមានចែងវិធានផ្ទៃក្នុងចាស់ដែលផ្តល់ការទទួលខុសត្រូវសំណងតែទៅលើប្រភពធនធានរបស់ទណ្ឌិត។ សង្គមស៊ីវិលជឿជាក់ថា ការធ្វើដូចនេះ នឹងជួយបើកឱ្យមានច្រកឱ្យអាចមានប្រភពថវិកាពីខាងក្រៅផ្សេងទៀត ក៏ដូចជាឱ្យ មានអ្នកជួយអនុវត្តន៍សំណងបានល្អ និងមានប្រសិទ្ធភាពជាង ហើយជនរងគ្រោះតុលាការកូនកាត់នេះទទួលបានជោគជ័យក្នុងការស្វែងរកយុត្តិធម៌សម្រាប់គេនិងជាគំរូនៃតុលាការលក្ខណៈអន្តរជាតិផ្សេង។

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសលាកប័ត្រព័ត៏មាននេះ មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ ឌី.អ៊ី.ឌី(**DED**) និង អូ.អេស.ជេ.អាយ(**OSJI**)ទេ។*

**ឧបត្ថម្ភមូលនិធិដោយៈ ឌី.អ៊ី.ឌី និង អូ.អេស.ជេ.អាយ**

### ព័ត៌មានសំខាន់:

➢ ប្រសិនបើលោកអ្នកចាប់អារម្មណ៍ ហើយចង់សាកសួរព័តិមានអំពីសាលាក្តីខ្មែរក្រហមបន្ថែមទៀត

**សូមទាក់ទង:**

- អង្គភាពគាំពារជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លេខទូរស័ព្ទ: ០២៣ ២១៤ ២៩១
- ផ្នែកកិច្ចការសាធារណ: លេខទូរស័ព្ទ: ០១២ ៤៨៨ ១៥៦

➢ ស្តាប់ *កម្មវិធីឃ្លាំមើលសាលាក្តី* ដែលមានផ្សាយបន្តផ្ទាល់ និងចាក់ផ្សាយឡើងវិញ តាមវិទ្យុ FM ១០២ រៀងរាល់ ថ្ងៃពុធ ម៉ោង ៥:៣០ - ៦:៣០ ល្ងាច ។

➢ សូមស្រាវជ្រាវព័តិមានបន្ថែមលើគេហទំព័រ **www.krtrial.info**